**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ម្ចាស់ ឬនាយកក្រុមហ៊ុន៖ ភី ភី អេស អ៊ី ស៊ី ឯ.ក**
លេខបញ្ជីពាណិជ្ជកម្ម៖ ០០០៣៥០៥៨ / MOC-៥៣១៦៦៥៩
លេខអត្តសញ្ញាណសហគ្រាសក្នុង ប.ស.ស.៖ ១០១៤១៧១
លេខគណនីធនាគារ៖ ៣៨៥៥០៣៤០៣៥១៩១២ (អេសស៊ីលីដា ភីអិលស៊ី)
អាសយដ្ឋាន៖ លេខផ្ទះ លេខផ្លូវ ផ្លូវជាតិលេខ៤ PPSEZ ភូមិ ឃុំ/សង្កាត់ កំបូល ក្រុង/ស្រុក/ខណ្ឌ កំបូល រាជធានី/ខេត្ត ភ្នំពេញ
ទូរស័ព្ទលេខ៖ ០២៣៩០១៣៧១ អ៊ីមែល (E-mail)៖ roberthwang@sec-acc.com

**សូមគោរពជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**តាមរយៈ**៖ លោកប្រធាននាយកដ្ឋានអធិការកិច្ចការងារ
**កម្មវត្ថុ** ៖ សំណើសុំព្យួរកិច្ចសន្យាការងារ កម្មករនិយោជិតចំនួន ៣៥នាក់ រយៈពេល ២៧ថ្ងៃ

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបថា ដោយមូលហេតុក្រុមហ៊ុនយើងខ្ញុំគ្មានការបញ្ជាទិញ ដូច្នេះក្រុមហ៊ុនយើងខ្ញុំស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ៣៥នាក់ (ស្រី ២៦នាក់) ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ៥១៨នាក់ (ស្រី ១៩៣នាក់) រយៈពេល ២៧ ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២៤ រហូតដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៤។

ក្នុងរយៈពេលនៃការព្យួរកិច្ចសន្យាការងារ ក្រុមហ៊ុនបានព្រមព្រៀងផ្តល់ប្រាក់ឧបត្ថម្ភជូនកម្មករនិយោជិត ៥០ ភាគរយ នៃប្រាក់ឈ្នួលអប្បបរមា។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាពិនិត្យ និងសម្រេចដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ២០២៤
ហត្ថលេខា និងត្រា
ម្ចាស់ ឬនាយក

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន ភី ភី អេស អ៊ី ស៊ី ឯ.ក PPSEC COMPANY LIMITED KINGDOM OF CAMBODIA

ឡេវ ភៃក

សូមភ្ជាប់មកជាមួយ:
- កិច្ចព្រមព្រៀងអំពីនីតិវិធីទូទាត់ជាមួយកម្មករនិយោជិតចំនួន ៣ច្បាប់
- បញ្ជីរាយនាមកម្មករនិយោជិតដែលស្នើសុំព្យួរកិច្ចសន្យាការងារចំនួន ៣ច្បាប់ និង ជា Soft Copy (Ms Excel) ទៅ E-mail: suspension@nea.gov.kh
- បញ្ជីបើកប្រាក់ឈ្នួលចុងក្រោយមុនពេលស្នើសុំព្យួរកិច្ចសន្យាការងារ
- វិញ្ញាបនបត្រពាណិជ្ជកម្ម (ច្បាប់ថតចម្លង) ចំនួន ៣ច្បាប់
- ប័ណ្ណពន្ធប៉ាតង់ (ច្បាប់ថតចម្លង) ចំនួន ៣ច្បាប់
- អាជ្ញាប័ណ្ណទេសចរណ៍ (ច្បាប់ថតចម្លង) ចំនួន ៣ច្បាប់ (វិស័យទេសចរណ៍)
- វិញ្ញាបនបត្រចុះបញ្ជីកាសហគ្រាស គ្រឹះស្ថាន ក្នុង ប.ស.ស. ចំនួន ៣ច្បាប់ (បើមាន)

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**កិច្ចព្រមព្រៀង**

**រវាង**

រោងចក្រ ភី ភី អេស អ៊ី ស៊ី ឯ.ក

និង

ប្រតិភូបុគ្គលិកដែលជាតំណាងកម្មករនិយោជិត

រោងចក្រ ភី ភី អេស អ៊ី ស៊ី ឯ.ក

**ស្តីអំពីការព្យួរកិច្ចសន្យាការងារ**

នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ ២០២៤ វេលាម៉ោង ០២រសៀល នៅក្នុងរោងចក្រ ភី ភី អេស អ៊ី ស៊ី ឯ. ក មានកិច្ចប្រជុំមួយរវាងតំណាងក្រុមហ៊ុន និងតំណាងកម្មកររោងចក្រ។

នៅក្នុងក្នុងអង្គប្រជុំនេះ នាយកក្រុមហ៊ុនបានជូនដំណឹងដល់កម្មករនិយោជិតទាំងអស់អំពីស្ថានភាពបច្ចុប្បន្ននៅក្នុងរោងចក្រ ថាដោយសារតែក្រុមហ៊ុនយើងខ្ញុំខ្វះការបញ្ជាទិញពីអតិថិជន ហេតុដូចនេះ ក្រុមហ៊ុនសម្រេចធ្វើការព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន៣៥នាក់ ស្រី២៦នាក់ ក្នុងចំណោមកម្មករនិយោជិតសរុប៥១៨នាក់ ស្រី១៩៣នាក់ រយៈពេល២៧ថ្ងៃ គឺចាប់ពីថ្ងៃទី០៥ ខែ សីហា ឆ្នាំ ២០២៤ រហូតដល់ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០២៤ ។ នៅក្នុងអំឡុងពេលនៃការព្យួរកិច្ចសន្យាការងារនេះ កម្មករនិយោជិតបានឯកភាពទទួលយកនូវការផ្តល់ជូនប្រាក់ឧបត្ថម្ភរបស់ក្រុមហ៊ុននូវការគណនា ៥០ ភាគរយនៃប្រាក់ឈ្នួលអប្បបរមា ជូនកម្មករនិយោជិតម្នាក់ៗដែលបើក នៅថ្ងៃទី ០៣ ខែសីហា ឆ្នាំ ២០២៤ តាមរយៈធនាគារ អេ ស៊ី លី ដា។

អង្គប្រជុំបានចប់នៅម៉ោង០៣ និង ១៥ នាទី រសៀល នាថ្ងៃខែឆ្នាំដដែលដោយភាគីទាំងសងខាងមានភាពស្និទ្ធស្នាល និងក្រោមស្មារតីយោគយល់គ្នា និងការសហការយ៉ាងរលូន។

ភ្នំពេញ ថ្ងៃទី៣១ ខែ កក្កដា ឆ្នាំ ២០២៤

**តំណាងកម្មករនិយោជិត**

ពេញ ស្រីណែត នេត ស្រីពៅ គុណ គឹមឃុន មិម សីមុន្នី

**ជ. នាយក្រុមហ៊ុន**

ក្រុមហ៊ុន ភី ភី អេស អ៊ី ស៊ី ឯ.ក

PPSEC COMPANY LIMITED

**ហ៊ើល សែន**